# អត្ថិភាពទស្សនវិជ្ជាខ្មែរក្នុងវិស័យផ្សេងៗក្នុងសង្គមខ្មែរ

*ដោយៈ* **បណ្ឌិត ប៉ាន់ ខុន្ថា**

*ប្រធានស្តីទីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*

*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*គ្រប់វិស័យទាំងអស់សុទ្ធតែមានទស្សនវិជ្ជានៅក្នុងនោះ ព្រោះវាមានចំណោទបញ្ហាទ្រឹស្តី គំនិត និងវិធីដោះស្រាយបញ្ហា ជាលក្ខណៈទស្សនវិជ្ជា ហើយគោលបំណង នៃការប្រតិបត្តិក្នុងគ្រប់វិស័យទាំងអស់សុទ្ធតែតម្រង់ទៅរកទស្សនវិជ្ជាទាំងអស់។*




*នេះជាការលើកឡើងខ្លះៗនូវគំនិតទស្សនវិជ្ជាខ្មែរក្នុងវិស័យផ្សេងៗក្នុងសង្គមខ្មែរ*

## ១–គំនិតទស្សនវិជ្ជាខ្មែរក្នុងវិស័យស្ថាបត្យកម្ម សំណង់ ប្រាសាទ

*បុព្វបុរសខ្មែរមានបង្កប់អត្ថន័យទស្សនវិជ្ជានៅក្នុងស្ថាបត្យកម្ម សំណង់ និងប្រាសាទយ៉ាងជ្រាលជ្រៅ។*

*បណ្ឌិត ឆយ យីហាង[1] យល់ឃើញថាៈ ការកសាងប្រាសាទទាំងអស់ ពិតជាកសាងចេញពីមូលដ្ឋានគ្រឹះទស្សនវិជ្ជាព្រហ្មញ្ញសាសនា និងពុទ្ធសាសនាមហាយាន មិនមែនកសាងឡើងដោយចេះតែនឹកឃើញ ដោយត្រឹមតែមាន ការគិតធម្មតាទេ។ ការកសាងប្រាសាទ មានគូទឹកព័ទ្ធជុំវិញ យកលំនាំតាមឥណ្ឌា។ ក្នុងទស្សនៈរបស់ខ្មែរយល់ថា គូទឹកបង្កប់នូវអត្ថន័យទស្សនវិជ្ជាៈ បំរើទស្សនវិជ្ជាសាសនាផង យកទឹកប្រើប្រាស់ក្នុងទីក្រុងផង*

[1] បណ្ឌិត ឆយ យីហ៊ាង  អតីតសាស្ត្រាចារ្យទស្សនវិជ្ជា និងជាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា។ លោកក៏ធ្លាប់ជាប្រធានដេប៉ាតឺម៉ង់ទស្សនវិជ្ជានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ប្រធានវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា, អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងទីប្រឹក្សារដ្ឋាភិបាល។

ជានយោបាយទឹកសម្រាប់កសិកម្មផង និងជារបាំងការពារនគរទប់ទល់នឹងសត្រូវផង។

លោក ដេវីឌ ឆាណ្ឌល័រ យល់ឃើញថា៖ ការកសាងប្រាសាទគឺ ដើម្បីឧទ្ទិសដល់ទេវៈផង ដើម្បីឧទ្ទិសដល់ព្រះអង្គផ្ទាល់ផង និងទុកជាផ្នូររបស់ព្រះអង្គនៅពេលសោយទីវង្គតផង។ ប្រាសាទជាលំនៅឋានសម្រាប់ពួកទេវៈ និងបុគ្គលគួរគោរពដែលបានស្លាប់ទៅនឹងបានឡើងឋានសួគ៌ (មិនមែនសម្រាប់តែព្រះរាជាប៉ុណ្ណោះទេ)។ ប្រាសាទក៏ជាផ្នូរខ្មោចផងដែរ សម្រាប់ទុកព្រះអដ្ឋិធាតុរបស់ព្រះរាជា។

## ២-គំនិតទស្សនវិជ្ជាខ្មែរក្នុងវិស័យចម្លាក់

បុព្វបុរសខ្មែរមានបង្កប់អត្ថន័យទស្សនវិជ្ជានៅក្នុងចម្លាក់។ ចម្លាក់នៅប្រាសាទបាយ័ន (នៅចុងសតវត្សទី១២ ក្នុង រជព្រះបាទជ័យវរ្ម័នទី៧) ប្រៀបដូចជាសៀវភៅសព្វវចនាធិប្បាយ១ក្បាលដ៏ធំ ដែលបានចារបង្ហាញប្រាប់អំពី ៖

- បែបបទនៃការរស់នៅ៖ ឋានានុក្រមមនុស្សក្នុងសង្គម
- វិស័យសុខាភិបាល៖ ការបង្កើតកូនដោយមានឆ្មប
- វិស័យកសិកម្ម៖ ប្រឡាយទឹក បន្ទៃ ដំណាំ
- វិស័យកីឡា៖ ចំបាប់ ជល់មាន់ ជល់ឆ្កែ ជល់ជ្រូក
- វិស័យសិក្សា៖ ការបង្ហាត់បង្រៀនរបស់បាគួបុរោហិត ដែលជាគ្រូក្នុងសម័យបុរាណ
- វិស័យសិល្បៈ៖ តន្ត្រី របាំ សៀក
- សម្បត្តិធម្មជាតិ៖ មនុស្ស សត្វ រុក្ខជាតិ ...
- វិស័យនេសាទ៖ ការនេសាទមានឧបករណ៍ដូចជា ព្រួល មង សន្ទូច ឈ្នាង លប និងសំភារៈផ្សេងៗ...
- វិស័យការពារជាតិ ៖ មានកងទ័ពថ្មើរជើង កងទ័ពដំរី កងទ័ពសេះ កងទ័ពជើងទឹក មានទូកចំបាំងដោយមានអ្នកចំបាំង និងអ្នកអុំ
- ជីវភាពរស់នៅ៖ ការផ្សារសាងសង់ សិប្បកម្ម។
- ទស្សនៈរបស់ប្រជាជនខ្មែរ៖ ទស្សនៈអំពីលោកិយ ទស្សនៈអំពីបរលោក។

## ៣-គំនិតទស្សនវិជ្ជាខ្មែរក្នុងវិស័យរបាំ

លក្ខណៈនៃរបាំបុរាណខ្មែរ គឺជាសិល្បៈគំនិត ដែលប្រើនិមិត្តរូបនិយម បង្កប់នូវគំនិតទស្សនវិជ្ជាយ៉ាងជ្រាលជ្រៅ។ របាំប្រពៃណីខ្មែរបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងធម្មជាតិដែលនៅជុំវិញខ្លួន និងជីវភាពរបស់ខ្មែរ។ បុព្វបុរសខ្មែរឃើញប្រឌិតរបាំប្រជាប្រិយ ពុំមែនមានន័យដាច់មុខសំរាប់តែកំសាន្តនោះទេ តែក៏បង្កប់នូវអត្ថន័យទស្សនវិជ្ជាដែលបកស្រាយបង្ហាញពីបទពិសោធន៍ពលកម្ម ផលិតកម្ម សកម្មភាពធ្វើកសិកម្ម នេសាទ បរបាញ់ សិប្បកម្ម ការបួងសួង ការឧទ្ទិស ... និងបង្ហាញពីវីធីធ្វើ

ការដើម្បីពង្រីក និងបង្កើនទិន្នផលឱ្យកាន់តែប្រសើរឡើង។

## ៤-គំនិតទស្សនវិជ្ជាខ្មែរក្នុងវិស័យតន្ត្រី

ខ្មែរមានសិល្បៈតន្ត្រីច្រើនប្រភេទ ហើយសិល្បៈតន្ត្រីទាំងនោះមានបង្កប់នូវអត្ថន័យទស្សនវិជ្ជាដូចជា ៖

- តន្ត្រីអារក្ខ៖ សំដែងការដឹងគុណ និងសុំឲ្យអារក្ខ អ្នកតាជួយថែរក្សា
- តន្ត្រីអាពាហ៍ពិពាហមង្គល៖ ដាស់ស្មារតីសាមគ្គីទាំងសងខាង
- តន្ត្រីមហោរី៖ តំណាងជីវិតរស់នៅពិតៗរបស់ខ្មែរ
- តន្ត្រីយីកេ៖ តំណាងសភាពទន់ភ្លន់
- តន្ត្រីបាសាក់ តន្ត្រីចាប៉ី៖ រំឭកក្បួនសាស្ត្រាអប់រំប្រៀនប្រដៅ
- តន្ត្រីអាយ៉ៃ តន្ត្រីស្គរឃ្មោះ៖ បំពេញបេសកកម្មលើសមរភូមិ ឬពេលដង្ហែសព)
- តន្ត្រីពិណពាទ្យ តន្ត្រីត្រៃលក្ខណ៍ តន្ត្រីប្រឹន៖ សុំពរជ័យពីវត្ថុសក្តិសិទ្ធិ
- តន្ត្រីឆៃយ៉ាំ៖ សម្តែងការស្វាគមន៍ ឧទ្ទិសមគ្គផល។

## ៥-គំនិតទស្សនវិជ្ជាខ្មែរក្នុងវិស័យអក្សរសិល្ប៍

តឹកតាងជាច្រើនបានឆ្លុះបញ្ចាំងពីផ្នត់គំនិតទស្សនវិជ្ជាខ្មែរ លក្ខណៈគតិពិចារណារបស់ប្រជាជនខ្មែរ ទំនៀមទំលាប់ ប្រពៃណី ជំនឿ ទស្សនៈរបស់ខ្មែរពិតៗ នៅក្នុងទេវកថា ព្រេងកថា រឿងព្រេងនិទានប្រជាប្រិយ ពាក្យជូនប្រជាប្រិយ ពាក្យបណ្តៅ កំរងសុភាសិត ល្បើក សាស្ត្រាល្បែង របាំប្រជាប្រិយ កំណាព្យ និង ចំរៀងប្រជាប្រិយ។ ក្នុងវិស័យសេដ្ឋកិច្ច អប់រំ សង្គមកិច្ច នយោបាយធម្មសាស្ត្រ នីតិសាស្ត្រ ... សុទ្ធតែមានតំណាលក្នុងរឿងនិទាន ចំរៀង សុភាសិត ពាក្យបណ្តៅ និងពាក្យជូនប្រជាប្រិយ។ អក្សរសិល្ប៍មិនគ្រាន់តែជាកញ្ចក់ឆ្លុះមើលការរស់នៅរបស់មនុស្សក្នុងសង្គមក្នុងសម័យកាលនីមួយៗទេ តែវាជាមធ្យោបាយមួយយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយគំនិតទស្សនវិជ្ជាផងដែរ។

## ៦-គំនិតទស្សនវិជ្ជាខ្មែរក្នុងវិស័យការអប់រំ

គេស្គាល់ជាតិនីមួយៗបានដោយសារលក្ខណៈរូបរបស់ជាតិ និងព្រលឹងជាតិ។ ពាក្យសម្តី កាយវិការ សម្លៀកបំពាក់ ចំណីអាហារ របៀបហូកចុក ... គឺជាផ្នែកមួយយ៉ាងសំខាន់បង្ហាញពីអត្តសញ្ញាណជាតិ និងរំលេចនូវតម្លៃគំនិតទស្សនវិជ្ជាផងដែរ។ បុព្វបុរសខ្មែរបានអប់រំកូនចៅតាំងតែពីការនិយាយស្តី ការស្លៀកពាក់ សីលធម៌ សុជីវធម៌ក្នុងការរស់នៅ។

ការសិក្សាសម័យដើមគឺសិក្សានៅតាមប្រាសាទឬវត្ត។ សម្តេចសង្ឃ រាជាគណៈ

ចៅអធិការ ព្រាហ្មណ៍ ជាសាស្ត្រាចារ្យ ជាគ្រូ។ វត្ត ឬ ប្រាសាទ ជាសាលារៀន ជាសាកលវិទ្យាល័យ ជាជម្រុកឬឃ្លាំងវិជ្ជាសព្វសារពើ។ វិជ្ជាគ្រប់បែបយ៉ាង ដូចជា អក្សរសាស្ត្រ គណិតសាស្ត្រ ហោរាសាស្ត្រ វិជ្ជាពេទ្យ វិជ្ជាវិស្វកម្ម វិជ្ជាស្ថាបត្យកម្ម វិជ្ជាចំលាក់ វិជ្ជាសិប្បកម្ម...ស្ថិតនៅក្នុងវត្ត។ អ្នកចេញពីវត្តសុទ្ធតែជាអ្នកដឹងក្តីដែលគេហៅថា អន្ទិត ឬ បណ្ឌិត ។

## ៧-គំនិតទស្សនវិជ្ជាខ្មែរក្នុងវិស័យសេដ្ឋកិច្ច

តាមរយៈប្រវត្តិសាស្ត្រខ្មែរបង្ហាញថា ខ្មែរជាអ្នកមានឧបនិស្ស័យកសិកម្ម ហើយយកកសិកម្មជាដួងព្រលឹងរបស់ខ្លួន។ សេដ្ឋកិច្ចខ្មែរផ្អែកលើផលិតកម្មកសិកម្ម។ កសិកម្មផ្សារភ្ជាប់ជាមួយព្រហ្មញ្ញសាសនា(ពិធីស្រោចទឹកលើលិង្គ) ពុទ្ធសាសនា(ពិធីច្រត់ព្រះនង្គ័ល) និងជំនឿជីវចលនិយម(ពីធីឡើងអ្នកតា សែនព្រេនម្ចាស់ទឹកម្ចាស់ដី អ្នកតាខ្យល់ អ្នកតាភ្លើង)។ ដើម្បីបានទឹកធ្វើកសិកម្ម ប្រជាជនខ្មែរប្រារព្ធពីធីឡើងអ្នកតា គឺជានិម្មិតរូបនៃការបង្កហេតុ និងការផ្តល់ ថាមពលរបស់ទឹក និងដីក្នុងការបង្កបង្កើនផលកសិកម្ម។

## ៨-គំនិតទស្សនវិជ្ជាខ្មែរក្នុងវិស័យច្បាប់

ប្រព័ន្ធទស្សនៈគតិយុត្ត និងធម្មសាស្ត្រខ្មែរ មានឆ្លុះបញ្ចាំងតាមរយៈទំនឹមទំនៀមពីបុរាណ អក្សរសិល្ប៍ប្រជាប្រិយខ្មែរ រឿងព្រេងនិទានប្រជាប្រិយ ល្បើក សាស្ត្រាល្បែង ចំរៀងកំណាព្យ ទាក់ទងទៅនឹងការកាត់សេចក្តីជាទូទៅ ឬអំពីចំណោទបញ្ហាយុត្តិធម៌ ដែលផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងសង្គមខ្មែរក្នុងបរិបទកាល និងលំហដែលអ្នកនិពន្ធរស់នៅ ឬធ្លាប់បានឆ្លងកាត់។ យើងមានសាស្ត្រាកឹងកន្ត្រៃគឺជាកំរងរឿងព្រេងខ្មែរចំនួន៥៣រឿង ដែលអត្ថបទដើមសរសេរដៃជាភាសាខ្មែរ ហើយត្រូវបានលោក អេដែន អែម៉ូនីញេរ បកប្រែសង្ខេបជាភាសាបារាំង និងចងក្រង បោះពុម្ពនៅឆ្នាំ១៨៧៨។ អត្ថបទដើមសាស្ត្រាកឹងកន្ត្រៃសរសេរដៃនេះ ត្រូវបានវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបោះពុម្ព ផ្សាយនាឆ្នាំ២០០១។ ក្រៅពីនេះ នៅមានរឿងព្រេងដទៃទៀតនៅក្នុងប្រជុំរឿងព្រេងខ្មែរ បណ្តាំក្រមង៉ុយ គតិលោក ក្នុងសៀវភៅស្រីហិតោបទេស របស់រិយបណ្ឌិត ប៉ាង ខាត់ និងគតិលោករបស់ឧកញ៉ា សុត្តន្តប្រីជាឥន្ទ ដែលទាក់ទង នឹង ទស្សវិជ្ជាច្បាប់ខ្មែរ សម្រាប់ប្រដៅមនុស្សតាមគតិលោក និងគតិធម៌។ ផ្តើមចេញពីការសង្កេត សិក្សាវិភាគ និង គិតពិចារណាតាមលំអានអក្សរសាស្ត្រ អក្សរសិល្ប៍ប្រជាប្រិយ រឿងព្រេងនិទាន រឿងល្បែង និង

តាមគន្ថធម្មសាស្ត្រ យើងអាចចងក្រងជាតម្រា ជាគោលការណ៍ច្បាប់ ឬជាប្រព័ន្ធទ្រឹស្តីយុត្តិធម៌ក្នុងទស្សនវិជ្ជាច្បាប់ខ្មែរ ទាំងច្បាប់ក្នុងន័យធម្មតា ទាំងច្បាប់ក្នុងន័យនីតិសាស្ត្រ។

## ៩-គំនិតទស្សនវិជ្ជាខ្មែរក្នុងវិស័យ សង្គម និងនយោបាយ

បុព្វបុរសខ្មែរ បានផ្សំការកសាងជាតិ និងទ្រឹស្តីនយោបាយ ទៅនឹងសាសនា។ ពិធីទេវរាជ និង ពិធីពុទ្ធរាជ ជាទស្សនវិជ្ជាមជ្ឈការអំណាច និងបង្កើតឯកភាពជាតិ។ ទន្ទឹមនឹង ពិធីទេវរាជ និង ពិធីពុទ្ធរាជ ក៏មានការប្រតិបត្តិទ្រឹស្តីបុគ្គលនិយម ដែលជាទស្សនវិជ្ជាមួយប្រើក្នុងការតបស្នងដឹងគុណវរៈជន។

ទ្រឹស្តីនយោបាយទាំង៣នេះ អ្នកស្រាវជ្រាវ ប្រវត្តិវិទូ ខ្មែរនិងបរទេស ស្ទើរតែទាំងអស់ តែងយល់ឃើញត្រឹមតែ ជា ជំនឿសាសនា ប៉ុន្តែតាមជាតុពិត វាគឺជាទស្សនវិជ្ជា ជាព្រលឹងខ្មែរ។ ទស្សនវិជ្ជានយោបាយនេះ ជាឋាមពលដ៏ខ្លាំងក្លា ដែលបានជំរុញការកសាងមហិទ្ធិតេជៈបេស្កាប្រទេសកម្ពុជាឲ្យមានអរិយធម៌រុងរឿងនាសម័យមហានគរ។

## សន្និដ្ឋាន

ទស្សនវិជ្ជាខ្មែរ ជាការសំយោគរវាងជំនឿជីវចលនិយម ជាមួយព្រហ្មញ្ញសាសនា និងពុទ្ធសាសនា។ ទស្សនវិជ្ជាក្នុងព្រហ្មញ្ញសាសនា និងទស្សនវិជ្ជាក្នុងពុទ្ធសាសនា ជាទស្សនវិជ្ជាមួយពោរពេញទៅដោយ ទ្រឹស្តីពុទ្ធិតក្កវិជ្ជា ទ្រឹស្តីតម្លៃ ទ្រឹស្តីតថភាព ទ្រឹស្តីសីលធម៌ ទ្រឹស្តីចិត្តវិទ្យា ទ្រឹស្តីមនុស្សវិទ្យា ទ្រឹស្តីច្បាប់ ទ្រឹស្តីអប់រំ ទ្រឹស្តីដឹកនាំនិងគ្រប់គ្រង ទ្រឹស្តីសង្គម និងនយោបាយ ... ដែលបានដើរតួនាទីយ៉ាងសំខាន់បំរើក្នុងវិស័យ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ការអប់រំ ... នៅក្នុងប្រទេសកម្ពុជាតាំងពីបុរាណកាលមកដល់សព្វថ្ងៃ។

តម្លៃនៃគំនិតទស្សនវិជ្ជាមានអត្ថិភាពនៅក្នុងវិស័យ សិល្បៈ សំណង់ ស្ថាបត្យកម្ម របាំតន្ត្រី អក្សរសិល្ប៍ ការអប់រំ សេដ្ឋកិច្ច នយោបាយ ច្បាប់ ជាដើមនេះ នៅតែមានតម្លៃមហាសាលសម្រាប់ប្រជាជននិងសង្គមខ្មែរសព្វថ្ងៃ។

## ឯកសារពិគ្រោះ


*១-កែវ ណារុំ៖* ***តន្ត្រីនិងជីវិតខ្មែរ*** *ឆ្នាំ ១៩៩៥។*

*២-ខ្ចូត ជីតា៖* ***ទស្សនវិជ្ជាខ្មែរសម័យអង្គរ*** *ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០៨។*

*៣-ត្រឹង ង៉ា៖* ***អរិយធម៌ខ្មែរ*** *ភ្នំពេញ គ.ស. ១៩៧៤ បោះពុម្ពលើកទី៣។*

*៤-ថាច់ វ៉ាន់ផាត និង កែវ សុកុន ៖* ***អាទិទេពក្រុងអង្គរ*** *ភ្នំពេញ រោងពុម្ពសច្ចៈ ឆ្នាំ១៩៧៣។*

*៥-ហ៊ែល ចំរើន៖* ***មរតកយុត្តិធម៌ខ្មែរ*** *បោះពុម្ពផ្សាយដោយរោងពុម្ពភ្នំពេញ ឆ្នាំ២០០៩-២០១០។*

*៦-អ៊ុំ ប៉ុម៖* ***សិក្សាស្វែងយល់អំពីគំនិតទស្សនវិជ្ជាខ្មែរ*** *ភ្នំពេញ បោះពុម្ពដោយបណ្ណាគារអង្គរ ឆ្នាំ២០០៥។*